# គ្រីស្ទបរិស័ទទាំងអស់គឺជាសង្ឃ

អ្នកនិពន្ធ រ៉ូហ្វ លេភិទ្យារ

## ពាក្យលំនាំ

បើសិនយើងចង់តែប្រើព្រះជាម្ចាស់ ដើម្បីអោយទ្រង់ជួយយើងនៅក្នុងជីវិតតែប៉ុណ្ណោះ នោះយើងប្រហែលជាមិនចាប់អារម្មណ៍លើសេចក្តីពិតផ្សេងៗនៅក្នុងមេរៀននេះទេ។ ទោះយ៉ាងណា ព្រះបានបើកសំដែងសេចក្តីពិតដែលសំខាន់ទាំងនេះសម្រាប់ការយល់ដឹង និង ការអនុវត្តដំណឹងល្អដោយត្រឹមត្រូវ ដូច្នេះគ្រីស្ទបរិស័ទត្រូវតែចាត់ទុកសេចក្តីពិតទាំងនេះថា មានសារៈសំខាន់ខ្លាំងណាស់។

ព្រះយេស៊ូវស្រឡាញ់ពួកជំនុំរបស់ទ្រង់ ហើយពួកជំនុំសំខាន់ចំពោះទ្រង់យ៉ាងខ្លាំង រហូតដល់ទ្រង់បានប្រទានជីវិតរបស់ទ្រង់ជំនួសពួកជំនុំ។ ដូច្នេះ គ្រីស្ទបរិស័ទណា ដែលស្រឡាញ់ព្រះគ្រីស្ទ ត្រូវតែស្រឡាញ់ពួកជំនុំដែលជាកូនក្រមុំរបស់ព្រះគ្រីស្ទផងដែរ។ ដូច្នេះ មេរៀននេះគួរតែសំខាន់សម្រាប់យើង ដើម្បីអោយពួកជំនុំនៅក្នុងប្រទេសកម្ពុជាអាចផ្គាប់ព្រះហឫទ័យដល់ព្រះគ្រីស្ទបាន។

## ការសង្ខេប

សេចក្តីពិតសំខាន់មួយចេញពីព្រះគម្ពីរគឺថា គ្រីស្ទបរិស័ទទាំងអស់គឺជាសង្ឃ (បូជាចារ្យ)។ នេះគឺជាភាពខុសគ្នាមួយរវាងព្រះគម្ពីរសញ្ញាចាស់ និងសញ្ញាថ្មី។ មានការផ្លាស់ប្តូរ ដោយសារតែការសុគតរបស់ព្រះយេស៊ូវនៅលើឈើឆ្កាង ហើយប្រព័ន្ធនៅក្នុងសម្ព័ន្ធមេត្រី (សញ្ញា) ថ្មីខុសគ្នានឹងប្រព័ន្ធនៅក្នុង សម្ព័ន្ធមេត្រី (សញ្ញា) ចាស់។ ដូច្នេះ ព្រះគម្ពីរសញ្ញាថ្មីមិនដែលហៅពួកអ្នកដឹកនាំពួកជំនុំថា សង្ឃ (បូជាចារ្យ) ទេ ហើយវាខុសពីសព្វថ្ងៃនេះ ដែលហៅពួកអ្នកដឹកនាំ/ ពួកគ្រូគង្វាលគ្រីស្ទបរិស័ទជា «សង្ឃ» ឬ «បូជាចារ្យ» នោះ។ នៅសព្វថ្ងៃនេះ ព្រះបានត្រាស់ហៅគ្រីស្ទបរិស័ទទាំងអស់អោយបម្រើទ្រង់។ មេរៀននេះមានសារៈសំខាន់ក្នុងការជួយយើងអោយយល់ពីអ្វីដែលព្រះគ្រីស្ទបានធ្វើសម្រាប់យើង ពីឯកសិទ្ធិ និងការទទួលខុសត្រូវរបស់យើងចំពោះព្រះ បញ្ជាក់អំពីសារៈសំខាន់របស់គ្រីស្ទបរិស័ទ ដោយមិនគិតពីអាយុ ភេទ ឬជាតិសាសន៍ ហើយបង្ហាញយើងអំពីរបៀបធ្វើអោយជីវិតពួកជំនុំស្របតាមព្រះបន្ទូលរបស់ព្រះត្រឹមត្រូវ។

## ពាក្យ «សង្ឃ» និង «បូជាចារ្យ»

មុនពេលយើងសិក្សាបន្តទៅទៀត យើងត្រូវតែគិតអំពីពាក្យថា «សង្ឃ» និង «បូជាចារ្យ» សិន។ ពាក្យដើមជាភាសាហេព្រើរ និងក្រិកគឺត្រូវបានបកប្រែថា «សង្ឃ» នៅក្នុងគម្ពីរខ្មែរបរិសុទ្ធ (លោក Hammond) និងបកប្រែថា «បូជាចារ្យ» នៅក្នុងគម្ពីរខ្មែរបច្ចុប្បន្ន (គខប ឬ Khmer Standard Version)។ ការបកប្រែខុសគ្នានេះគឺដោយព្រោះមានការលំបាកក្នុងការស្វែងរកពាក្យភាសាខ្មែរមួយ ដែលនឹងជួយផ្តល់អោយជនជាតិខ្មែរនូវគំនិតត្រឹមត្រូវអំពី សង្ឃ (បូជាចារ្យ) នៅក្នុងព្រះគម្ពីរសញ្ញាចាស់។ ពាក្យភាសាហេព្រើរសម្រាប់សង្ឃ (បូជាចារ្យ) គឺ (כֹּהֵן *kōhēn* ភាសាអើរ៉ាម כָּהֵן, *kāhēn*) សំដៅលើមនុស្សម្នាក់ ដែលបម្រើនៅក្នុងតំណែងជាផ្លូវការមួយនៅក្នុង ឬជុំវិញកន្លែងថ្វាយបង្គំបរិសុទ្ធ

មួយ ហើយសម្របសម្រួលរវាងព្រះ និងមនុស្ស។ នៅក្នុងភាសាបុរាណផ្សេងៗទៀតស្រដៀងនឹងភាសាហេព្រើរ ពាក្យថា សង្ឃ (បូជាចារ្យ) នេះក៏បានសំដៅទៅលើអ្នកធ្វើការខាងសាសនាផងដែរ។ ពាក្យភាសាក្រិកដែលបកប្រែថា «សង្ឃ» ឬ «បូជាចារ្យ» ដែលគេបានប្រើនៅក្នុងសញ្ញាថ្មីគឺ ἱερεύς (*hiereus*)។ ពាក្យភាសាក្រិកដែលទាក់ទងនឹងពាក្យនេះមានរួមទាំងគុណនាម ἱερός (*hieros*, «បរិសុទ្ធ») និងនាម ἀρχιερεύς (*archiereus*, «សម្ដេចសង្ឃ») និង ἱερόν (*hieron*, «ព្រះវិហារ»)។ ពាក្យភាសាក្រិកសំដៅទៅអ្នកដែលបម្រើព្រះរបស់គេនៅព្រះវិហារ (ឬ ទីបរិសុទ្ធ)។ ដូច្នេះយើងឃើញថា ពាក្យភាសាក្រិកមានអត្ថន័យ ស្រដៀងគ្នានឹងពាក្យភាសាហេព្រើរ។

ដូច្នេះ យើងអាចបកប្រែពាក្យភាសាហេព្រើរ និងភាសាក្រិកដោយពាក្យ «សង្ឃ» នៅក្នុងវប្បធម៌ខ្មែរបាន ដោយព្រោះនៅក្នុងប្រទេសកម្ពុជា «សង្ឃ» គឺជាមនុស្ស ដែលបម្រើនៅក្នុងតំណែងជាផ្លូវការមួយនៅក្នុង ឬជុំវិញកន្លែងថ្វាយបង្គំបរិសុទ្ធ។ ប្រជាជនខ្មែរក៏ប្រើសង្ឃ ដើម្បីធ្វើការសម្របសម្រួលរវាងពួកគេ និងវិញ្ញាណ ផ្សេងៗផងដែរ។ វប្បធម៌ភាគច្រើនរាប់ពាន់ឆ្នាំកន្លងទៅ មានមនុស្សធ្វើការនៅក្នុងតំណែងនេះ ហើយពាក្យភាសាហេព្រើរបានសំដៅទៅលើមនុស្សមានតំណែងនេះ។ ទោះយ៉ាងណា បញ្ហាគឺថា នៅពេលប្រជាជនខ្មែរលឺពាក្យថា «សង្ឃ» ពួកគេគិតអំពីសង្ឃព្រះពុទ្ធសាសនាខ្មែរ ហើយវាខុសគ្នាខ្លាំងណាស់ជាមួយនឹង «សង្ឃ» នៅក្នុងព្រះគម្ពីរ។ ហេតុផលមួយគឺដោយព្រោះ ព្រះដ៏ជាអាទិករ ដែលបានបើកសំដែងអង្គទ្រង់នៅក្នុងព្រះគម្ពីរ មានលក្ខណៈខុសគ្នាយ៉ាងខ្លាំងពីវិញ្ញាណទាំងឡាយ។ មុខងារសំខាន់មួយរបស់សង្ឃ/បូជាចារ្យនៅក្នុងព្រះគម្ពីរសញ្ញាចាស់គឺត្រូវថ្វាយយញ្ញបូជា ដែលជាមូលហេតុមួយ ដែលគម្ពីរខ្មែរបច្ចុប្បន្ន (គខប) បានបកប្រែភាសាហេព្រើរ כֹּהֵן ជាពាក្យ «បូជាចារ្យ»។

បញ្ហាគឺថា ទោះបីជានៅក្នុងវប្បធម៌ជាច្រើនក្នុងរយៈពេលរាប់ពាន់ឆ្នាំ មានអ្នកធ្វើការជាផ្លូវការខាងសាសនា ដែលបម្រើនៅព្រះវិហារ ហើយពួកគេជាពួកអ្នកសម្របសម្រួលក៏ដោយ តើយើងគួរតែប្រើពាក្យដូចគ្នាសម្រាប់មនុស្ស ដែលបំពេញមុខងារសម្រាប់ព្រះដ៏ពិតនិងមនុស្ស ដែលបំពេញមុខងារសម្រាប់ព្រះក្លែងក្លាយឬទេ? ឬតើយើងគួរតែប្រើពាក្យខុសគ្នាមួយ ដើម្បីជួយបង្ហាញភាពខុសគ្នារវាងព្រះដ៏ពិត និងព្រះក្លែងក្លាយដែរឬទេ។ នេះមិនមែនជាសំនួរងាយស្រួលឆ្លើយនោះទេ។ ដោយសារបញ្ហានេះនៅក្នុងប្រវត្តិសាស្ត្រក៏មានការផ្លាស់ប្តូរការប្រើពាក្យភាសាហេព្រើរផងដែរ។

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ជាភាសាហេព្រើរដើម គេបានប្រើពាក្យតែមួយសម្រាប់ពួកសង្ឃ (បូជាចារ្យ) ដែលបានបម្រើព្រះដ៏ពិត (កូនរបស់អើរ៉ុន) និងសម្រាប់ពួកសង្ឃរបស់ព្រះបាល (ឧទាហរណ៍ ២ពង្សាវតារក្សត្រ ១០: ១៩) ប៉ុន្តែក្រោយមកក្នុងប្រវត្តិសាស្ត្រ គេបានរឹតបន្តឹងលើពាក្យភាសាហេព្រើរអោយប្រើសម្រាប់តែពួកសង្ឃលេវីប៉ុណ្ណោះ ដូច្នេះហើយគេបានប្រើពាក្យផ្សេងមួយសម្រាប់ពួកសង្ឃ ដែលបម្រើព្រះដទៃ។ ការបកប្រែព្រះគម្ពីរសញ្ញាចាស់ភាសាហេព្រើរទៅជាភាសាដទៃ បានប្រើពាក្យផ្សេងគ្នាសម្រាប់ពួកសង្ឃដែលព្រះបានចាក់ប្រេងតាំង ត្រូវជាកូនរបស់អើរ៉ុន និងពួកសង្ឃ ដែលបម្រើព្រះដទៃ។

ដោយព្រោះមិនមានពាក្យណា ដែលនឹងផ្តល់អោយប្រជាជនខ្មែរនូវអត្ថន័យពេញលេញអំពីពាក្យដើមនៅក្នុងព្រះគម្ពីរ នោះយើងនឹងមិននិយាយថា ពាក្យមួយណា (សង្ឃ ឬ បូជាចារ្យ)ខុស ឬត្រូវឡើយ។ យើងនឹងពន្យល់អំពី

លក្ខណៈរបស់ពួកសង្ឃនៅក្នុងព្រះគម្ពីរ ការផ្លាស់ប្តូរដែលមានដោយសារការសុគតរបស់ព្រះយេស៊ូវនិង សម្ព័ន្ធមេត្រីថ្មី ហើយ និងការអនុវត្តសម្រាប់គ្រីស្ទបរិស័ទនៅសព្វថ្ងៃនេះ។

## តួនាទីរបស់សង្ឃ (បូជាចារ្យ) នៅក្នុងព្រះគម្ពីរសញ្ញាចាស់

តួនាទីរបស់សង្ឃនៅក្នុងព្រះគម្ពីរសញ្ញាចាស់គឺត្រូវសម្រុះសម្រួលរវាងព្រះដ៏បរិសុទ្ធ ដែលបានបង្កើតរបស់សព្វសារពើ និងមនុស្សមានបាប ហើយត្រូវបង្រៀនបញ្ញត្តិរបស់ព្រះដល់អ៊ីស្រាអែល (លេវីវិន័យ ១០:១១; ចោទិយកថា ២៤:៨; ៣១:៩-១៣; ៣៣:១០) ហើយត្រូវជួយនាំការថ្វាយបង្គំព្រះនៅក្នុងរបៀប ដែលផ្គាប់ព្រះហឫទ័យដល់ព្រះ គឺអោយស្រុបតាមព្រះបន្ទូលដែលទ្រង់បើកសំដែង (១របាក្សត្រ ១៦; នេហេមា ១២) ត្រូវយល់ដឹងអំពីបំណងព្រះហឫទ័យរបស់ព្រះ (និក្ខមនំ ២៨:៣០; លេវីវិន័យ ៨:៨) និងនៅក្នុងរឿងក្តីផ្លូវច្បាប់ពិបាកៗ (ចោទិយកថា ១៧:៨-១១) ត្រូវអោយពរដល់បណ្តាជន (ជនគណនា ៦:២៣-២៧) ហើយត្រូវពិនិត្យមើលបណ្តាជន ដើម្បីប្រកាសថា អ្នកនោះជាមនុស្សបរិសុទ្ធ ឬមិនបរិសុទ្ធ (លេវីវិន័យ ១៣-១៥)។ ពួកសង្ឃទូលអង្វរជំនួសបណ្តាជននៅចំពោះព្រះ ហើយជួយតំណាងបណ្តាជននៅពេលពួកគេថ្វាយយញ្ញបូជាទៅព្រះជាម្ចាស់។ តាមធម្មតាសង្ឃមិនមែនជាអ្នកដែលបានសំឡាប់សត្វយញ្ញបូជាទេ ប៉ុន្តែគាត់ប្រោះឈាមរបស់សត្វនោះ នៅអាសនាជំនួសអោយអ្នកដែលបានថ្វាយនោះ (ឧទាហរណ៍ លេវីវិន័យ ១:៣-៩)។ ពួកសង្ឃត្រូវតែជាកូនរបស់អើរ៉ុន (និក្ខមនំ ២៨:១-២៩:៤៦; លេវីវិន័យ ៨:១-៩:២៤)។

ទោះយ៉ាងណា យើងត្រូវតែចងចាំថា នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ជាតិសាសន៍អ៊ីស្រាអែលទាំងមូលត្រូវតែធ្វើជា «នគរដែលសុទ្ធតែជាសង្ឃ និងជាសាសន៍បរិសុទ្ធ» (និក្ខមនំ ១៩:៦)។ ប៉ុន្តែបន្ទាប់ពីការចាប់ផ្តើមសម្ព័ន្ធមេត្រីរបស់ម៉ូសេនៅស៊ីណាយ ព្រះអង្គបានជ្រើសរើសពូជអំបូរលេវី ដើម្បីអោយមានតំណែងពិសេស ហើយគ្រួសាររបស់អើរ៉ុននៅក្នុងពូជអំបូរលេវី ត្រូវបានព្រះចាក់ប្រេងតាំងអោយមានតំណែងជាសង្ឃ (បូជាចារ្យ) (និក្ខមនំ ២៨:១-២៩:៤៦; ៣២:២៥-២៩; ជនគណនា ៣:៤០-៥១)។

តំណែងជាសង្ឃតាមពូជរបស់អើរ៉ុនគឺជា តំណែងជាសង្ឃជាផ្លូវការនៅក្នុងសម្ព័ន្ធមេត្រីនៅភ្នំស៊ីណាយ ហើយទំនុកដំកើង ១១០:៤ និយាយអំពីដំណែងជាសង្ឃ (មុខងារជាបូជាចារ្យ) មួយប្រភេទទៀត គឺដំណែងជាសង្ឃតាមរបៀបលោកម៉ិលគីស្សាដែក (លោកុប្បត្តិ ១៤:១៨-២០)។ អ្នកនិពន្ធកណ្ឋហេព្រើរពិពណ៌នាអំពីព្រះយេស៊ូវគ្រីស្ទជាសម្តេចសង្ឃ (មហាបូជាចារ្យ) នៅក្នុងសម្ព័ន្ធមេត្រីថ្មីតាមរបៀបលោកម៉ិលគីស្សាដែក (ហេព្រើរ ៥:៦-១០; ៦:២០; ៧:១៧)។

## ព្រះយេស៊ូវជាសម្តេចសង្ឃ (មហាបូជាចារ្យ) ដ៏អស្ចារ្យ

ព្រះគ្រីស្ទគឺជាអ្នកសម្រុះសម្រួល (ស្ពានមេត្រី) តែមួយរវាងព្រះជាម្ចាស់ និងមនុស្សលោកពីព្រោះទ្រង់គឺជាសម្តេចសង្ឃតាមរបៀបលោកម៉ិលគីស្សាដែក (ហេព្រើរ ៥:១-១០)។ យញ្ញបូជាទាំងអស់នៅក្នុងព្រះគម្ពីរសញ្ញាចាស់បានចង្អុលទៅកាន់ ការសុគតរបស់ព្រះយេស៊ូវនៅលើឈើឆ្កាង ធ្វើជាយញ្ញបូជាពិតប្រាកដតែមួយ ដែលនាំអោយព្រះអត់ទោសអំពើបាបរបស់យើង ហើយយើងបានផ្សះផ្សាជាមួយនឹងព្រះវិញ។ ដូច្នេះ ព្រះយេស៊ូវគឺជាអ្នកសម្របសម្រួលពិតប្រាកដតែម្នាក់រវាងព្រះ និងមនុស្ស (១ធីម៉ូថេ ២:៥)។ នៅពេលព្រះយេស៊ូវបានសុគតនៅលើ

ឈើឆ្កាង វាំងននព្រះវិហារបានរហែកជាពីរ ដើម្បីបង្ហាញថា តាមរយៈការសុគតរបស់ទ្រង់ ទ្រង់បានបើកផ្លូវសម្រាប់យើងចូលកាន់ព្រះជាម្ចាស់។ ដូច្នេះ ការអនុវត្តមួយពីការសុគតរបស់ព្រះយេស៊ូវនៅលើឈើឆ្កាងគឺថា យើងលែងត្រូវការពួកសង្ឃ (បូជាចារ្យ)ដូចក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលថ្វាយយញ្ញបូជាទៀតហើយ។ បើសិននិយាយថាយើងត្រូវការពួកសង្ឃដូចក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាការបដិសេធអ្វី ដែលព្រះយេស៊ូវបានសម្រេចនៅលើឈើឆ្កាង។ នេះមានន័យថា តួនាទីរបស់ពួកអ្នកដឹកនាំពួកជំនុំនៅក្នុង សម្ព័ន្ធមេត្រីថ្មីគឺ ខុសពីតួនាទីរបស់ពួកសង្ឃរបស់អ៊ីស្រាអែលនៅក្នុងសម្ព័ន្ធមេត្រីចាស់។

## អ្នកជឿទាំងអស់គឺជាសង្ឃ

ដូច្នេះ ដោយសារអ្វីដែលព្រះយេស៊ូវបានធ្វើនៅលើឈើឆ្កាង និងដោយសារយើងនៅក្រោមសម្ព័ន្ធមេត្រីថ្មី នោះព្រះគម្ពីរសញ្ញាថ្មីមិនដែលហៅពួកអ្នកដឹកនាំពួកជំនុំជា «ពួកសង្ឃ» (បូជាចារ្យ)នោះឡើយ ប៉ុន្តែ បង្រៀនថា គ្រីស្ទបរិស័ទទាំងអស់គឺជាសង្ឃ (១ពេត្រុស ២:៥, ៩; វិវរណៈ ១:៦; ៥:១០;២០:៦ ប្រៀបធៀបនឹងនិក្ខមនំ ១៩:៦) ។ ដូច្នេះ នៅក្នុងព្រះគម្ពីរសញ្ញាចាស់មានតែពួកលេវីមួយចំនួនទេ ដែលអាចក្លាយជាសង្ឃ ហើយពួកសាសន៍ដទៃមិនអាចទេ ជនជាតិអ៊ីស្រាអែលដែលមិនមកពីពូជអំបូរលេវីក៏មិនអាច ហើយសូម្បីតែពួកលេវីជាច្រើនក៏មិនអាចដែរ ។ ឥឡូវនេះ គ្រីស្ទបរិស័ទទាំងអស់ មិនថាសាសន៍យូដា ឬសាសន៍ដទៃ គឺជាសង្ឃ។ នេះមានន័យថា គ្រីស្ទបរិស័ទមិនត្រូវការអ្នកសង្រួបសង្រួម (ស្ពានមេត្រី)រវាងព្រះ និងយើងក្រៅពីព្រះយេស៊ូវឡើយ (១ធីម៉ូថេ ២:៥)។ បើសិនយើងនិយាយថា យើងត្រូវការអ្នកសម្របសម្រួលម្នាក់ទៀត នោះយើងបដិសេធអ្វី ដែលព្រះយេស៊ូវបានធ្វើនៅលើឈើឆ្កាងហើយ។

ការនិយាយថា យើងទាំងអស់គ្នាគឺជាសង្ឃ ក៏ប្រាប់យើងអំពីទំនួលខុសត្រូវរបស់គ្រីស្ទបរិស័ទទាំងអស់ផងដែរ ។ យើងទាំងអស់គ្នាត្រូវតែមានជីវិតបរិសុទ្ធ (១ពេត្រុស ១:១៦)។ ជារឿយៗនៅក្នុងសាសនារបស់មនុស្ស មានពីរថ្នាក់ គឺមានការបែងចែកមួយរវាងសង្ឃដែលជាមនុស្សបរិសុទ្ធពិសេស និងអ្នកដើរតាមសាសនាធម្មតា (ពួកឃរាវាស ពួកគ្រហស្ថ ពួកអ្នកក្រៅពីវិជ្ជាជីវៈ)។ យើងមើលឃើញការបែងចែកនេះនៅក្នុងព្រះពុទ្ធសាសនានៅក្នុងប្រទេសកម្ពុជា គឺសង្ឃព្រះពុទ្ធសាសនាគឺ ជាមនុស្សបរិសុទ្ធពិសេស ប៉ុន្តែមនុស្សធម្មតាមិនចាំបាច់ធ្វើតាមច្បាប់ដូចគ្នា ឬត្រូវតែបរិសុទ្ធដូចសង្ឃនោះទេ។ ការបែងចែកនេះពិតជាផ្ទុយទាំងស្រុងទៅនឹងជំនឿគ្រីស្ទបរិស័ទ។ មិនមានកន្លែងណានៅក្នុងព្រះគម្ពីរសញ្ញាថ្មី ដែលផ្តល់ច្បាប់សម្រាប់ក្រុមពួកសង្ឃពិសេសមួយ និងច្បាប់ផ្សេងទៀតសម្រាប់គ្រីស្ទបរិស័ទធម្មតាឡើយ។ យើងទាំងអស់គ្នាត្រូវតែបរិសុទ្ធ ហើយប្រើជីវិតដើម្បីបម្រើព្រះ និងថ្វាយរូបកាយរបស់យើងជាយញ្ញបូជារស់ដល់ទ្រង់ (រ៉ូម ១២:១-២)។

តង្វាយដទៃទៀត ដែលអ្នកជឿថ្វាយទៅកាន់ព្រះគឺ «សេចក្តីស្រឡាញ់ជាបងប្អូន» (អេភេសូរ ៥:១, ២) «ការប្រព្រឹត្តល្អ» (ហេព្រើរ ១៣:១៦) «ទ្រព្យសម្បត្តិ» ដើម្បីជួយដល់អ្នកដទៃ (ហេព្រើរ ១៣:១៦) និង «ការបំរើ» អ្នកដទៃ (ភីលីព ២:១៧)។ យើងមិនទុកអោយអ្នកណាផ្សេងរៀបចំការថ្វាយបង្គំសម្រាប់យើងទេ គឺយើងត្រូវតែធ្វើដោយខ្លួនឯងវិញ។ យើងមិនទុកអោយពួកសង្ឃច្រៀងសម្រាប់យើងទេ គឺយើងទាំងស្រីទាំងប្រុសច្រៀងដោយខ្លួនឯងវិញ (កាឡាទី ៣:២៨; អេភេសូរ ៥:១៩)។ នេះមិនមានន័យថា មិនមានមុខងារពិសេសសម្រាប់គ្រីស្ទ បរិស័ទខ្លះ ដែល

ព្រះបានត្រាស់ហៅអោយបំពេញការបម្រើជាក់លាក់នោះទេ ពីព្រោះគ្រីស្ទបរិស័ទខ្លះពិតជាមានការបម្រើពិសេសមួយ (១កូរិនថូស ១២:២៨; អេភេសូរ ៤:១១...) ប៉ុន្តែមនុស្សទាំងនេះមិនមានការចូលទៅចំពោះព្រះពិសេសជាងគ្រីស្ទបរិស័ទដទៃទៀតឡើយ ហើយពួកគេក៏មិនមែនជាពួកអ្នកសម្របសម្រួលរវាង ព្រះជាម្ចាស់ និងមនុស្សដែរ។

ព្រះគម្ពីរសញ្ញាថ្មីប្រើពាក្យដែលព្រះគម្ពីរសញ្ញាចាស់ប្រើសម្រាប់ការបម្រើរបស់ពួកសង្ឃ ប៉ុន្តែព្រះគម្ពីរសញ្ញាថ្មីបានអនុវត្តពាក្យទាំងនោះនៅក្នុងរបៀបថ្មី។

សារដំណឹងល្អអំពីការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូវផ្លាស់ប្តូរអ្វីដែលយើងធ្វើ ដើម្បីថ្វាយបង្គំព្រះ។ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ការថ្វាយបង្គំជាប់ទាក់ទងយ៉ាងជិតស្និទ្ធជាមួយព្រះវិហារ ពួកសង្ឃ ដង្វាយ និងយញ្ញបូជា។ ឧបមារថា អ្នកជាសាសន៍យូដាម្នាក់នៅក្នុងសតវត្សទីមួយដែលក្លាយជាគ្រីស្ទបរិស័ទម្នាក់។ ប្រជាជនរបស់អ្នកបានថ្វាយបង្គំព្រះតាមរយៈពួកសង្ឃ និងការថ្វាយដង្វាយ និងយញ្ញបូជា។ ឥឡូវ គេបានប្រាប់អ្នកថា យើងលែងថ្វាយបង្គំព្រះតាមរបៀបនេះទៀតហើយ។ តើអ្នកគិតយ៉ាងដូចម្តេច? អ្នកនឹងសួរថា អញ្ចឹងតើយើងថ្វាយបង្គំព្រះដោយរបៀបយ៉ាងដូចម្តេចទៅ? មានចម្លើយនៅក្នុង រ៉ូម ១២:១; ហេព្រើរ ១៣:១៥; ១ពេត្រុស ២:៤។ តើហេតុអ្វីប៉ុលនិយាយថា «យញ្ញបូជារស់» នៅក្នុងរ៉ូម ១២:១? ពីព្រោះពួកគេមានទំលាប់សំឡាប់យញ្ញបូជាដែលគេថ្វាយ។ ប៉ុន្តែឥឡូវនេះ ជំនួសឲ្យការនាំសត្វទៅថ្វាយព្រះហើយ*សម្លាប់*សត្វនោះ យើងនាំយកជីវិតរបស់យើងផ្ទាល់ទៅថ្វាយព្រះ និងថ្វាយរូបកាយរបស់យើងជាយញ្ញបូជា*រស់* ដោយសារតែសេចក្តីមេត្តាករុណារបស់ព្រះ នៅក្នុងការសង្គ្រោះយើងតាមរយៈព្រះយេស៊ូវវិញ។ យើងមិនថ្វាយយញ្ញបូជាខាងសាច់ឈាមទេ (សត្វ...-ល-) ប៉ុន្តែយើងថ្វាយយញ្ញបូជាខាងវិញ្ញាណវិញ (១ពេត្រុស ២:៤)។ យើងថ្វាយការសរសើរ និងប្រកាសអំពីព្រះនាមរបស់ព្រះយេស៊ូវ (ហេព្រើរ ១៣:១៥)។ សូមកត់សំគាល់ថា នៅក្នុងខគម្ពីរទាំងនេះ អ្នកនិពន្ធថ្លែងថា ព្រះសព្វព្រះហឫទ័យ និងទទួលយកការថ្វាយបង្គំបែបនេះ។ យើងមិនមានពួកសង្ឃដូចនៅក្នុងព្រះគម្ពីរសញ្ញាចាស់ទៀតទេ ប៉ុន្តែគ្រីស្ទបរិស័ទទាំងអស់គឺជា «ពួកសង្ឃ» ហើយព្រះគ្រីស្ទ គឺជាសម្តេចសង្ឃរបស់យើងរាល់គ្នា។ លើសពីនេះ លោកប៉ុលសរសេរនៅក្នុងរ៉ូម ១:៩ ថា «ព្រះដែលខ្ញុំបម្រើដោយវិញ្ញាណខ្ញុំ ក្នុងដំណឹងល្អពីព្រះរាជបុត្រាទ្រង់»។ ពាក្យ «បម្រើ» នៅទីនេះគឺជាពាក្យដែលត្រូវបានបកប្រែជាការថ្វាយបង្គំផងដែរ។ របៀបដែលលោកប៉ុលថ្វាយបង្គំព្រះមិនមែនជាការថ្វាយយញ្ញបូជាទេ ប៉ុន្តែដោយការប្រកាសដំណឹងល្អវិញ។ ដូច្នេះ ការអធិប្បាយគឺជាសកម្មភាពថ្វាយបង្គំមួយ។ ដូច្នេះ វាខុសបើ និយាយថា ពេលវេលាច្រៀងនៅក្នុងពួកជំនុំ គឺជាការថ្វាយបង្គំ ប៉ុន្តែមិននិយាយថា សេចក្តីអធិប្បាយ គឺជាការថ្វាយបង្គំនោះ។ ការអធិប្បាយ គឺជាសកម្មភាពថ្វាយបង្គំរបស់អ្នកអធិប្បាយ។ អស់អ្នកដែលស្តាប់ព្រះបន្ទូលរបស់ព្រះ បានស្តាប់ព្រះបន្ទូលដែលដឹកនាំពួកគេឲ្យថ្វាយបង្គំព្រះក្នុងរបៀបដែលព្រះសព្វព្រះហឫទ័យ ដោយគេរីកចម្រើននៅក្នុងការយល់ដឹងអំពីព្រះ សេចក្តីស្រលាញ់របស់ទ្រង់សម្រាប់យើង ដែលឃើញនៅក្នុងព្រះគ្រីស្ទ និងបំណងព្រះហឫទ័យទ្រង់សម្រាប់យើង ដែលទាំងអស់នេះគឺតាមរយៈការរៀនព្រះគម្ពីរ។ នៅក្នុងរបៀបនេះ អ្នកអធិប្បាយគឺជា «អ្នកដឹកនាំថ្វាយបង្គំ» ម្នាក់ ពីព្រោះគាត់កំពុងដឹកនាំមនុស្សទៅកាន់ព្រះ និងថ្វាយបង្គំព្រះតាមរបៀបដែលផ្គាប់ព្រះហឫទ័យទ្រង់។ លើសពីនេះ លោកប៉ុលនិយាយថា ការអធិប្បាយដំណឹងល្អមិនគ្រាន់តែជាសកម្មភាពបម្រើព្រះ ថ្វាយបង្គំព្រះប៉ុណ្ណោះទេ ប៉ុន្តែក៏ជាកាតព្វកិច្ចបែបពួកសង្ឃផងដែរ (រ៉ូម ១៥:១៥-១៦)។

ដូច្នេះ តួនាទីរបស់ពួកសង្ឃបានផ្លាស់ប្តូរពីព្រះគម្ពីរសញ្ញាចាស់។ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ពួកសង្ឃបានថ្វាយបង្គំដោយការថ្វាយយញ្ញបូជា និងដង្វាយទៅតាមក្រឹត្យវិន័យ។ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី លោកប៉ុលនិយាយថា គាត់ថ្វាយបង្គំព្រះដោយការប្រកាសអំពីព្រះយេស៊ូវ ដែលជាយញ្ញបូជាពិតតែមួយដែលព្រះអាចទទួលយកបាន។ លោកប៉ុលមិនថ្វាយយញ្ញបូជាទេ ប៉ុន្តែតាមរយៈការប្រកាសដំណឹងល្អ ពួកសាសន៍ដទៃអាចជាដង្វាយដែលព្រះទទួលយកបាន។ ម្តងទៀត បទគម្ពីរនេះបង្ហាញថា យើងត្រឡប់ជាដង្វាយដែលព្រះទទួលយកបានតាមរយៈព្រះយេស៊ូវ ហើយយើងបរិសុទ្ធតាមរយៈព្រះវិញ្ញាណបរិសុទ្ធ។

## ការអនុវត្តសម្រាប់ជីវិតពួកជំនុំ

សេចក្តីពិតដែលថា គ្រីស្ទបរិស័ទទាំងអស់គឺជាសង្ឃ (បូជាចារ្យ) គឺជាផ្នែកសំខាន់មួយនៃសេចក្តីបង្រៀនរបស់ព្រះគម្ពីរអំពីពួកជំនុំ។ គ្រីស្ទបរិស័ទមិនគួរហៅពួកអ្នកដឹកនាំរបស់ពួកគេជា «សង្ឃ» ឬ «បូជាចារ្យ» ទេ ពីព្រោះការហៅនេះប្រឆាំងទាំងស្រុងទៅនឹងសេចក្តីបង្រៀននិងការអនុវត្តនៅក្នុងព្រះគម្ពីរសញ្ញាថ្មី។ ដោយសារយើងទាំងអស់គ្នាគឺជាសង្ឃ នោះយើងមានទំនួលខុសត្រូវក្នុងការបម្រើគ្នាទៅវិញទៅមក នៅក្នុងរូបកាយរបស់ព្រះគ្រីស្ទ ហើយជួយគ្នាអោយរីកចម្រើនឡើង (១កូរិនថូស ១២:១២-៣១; កូល៉ុស ៣:១៥-១៦)។ ប៉ុន្តែ នៅពេលយើងធ្វើដូច្នេះ យើងត្រូវតែយកចិត្តទុកដាក់ថា អ្វីទាំងអស់ដែលយើងនិយាយ បង្រៀន និងប្រព្រឹត្តក្នុងការបម្រើគ្នាទៅវិញទៅមកគឺ ត្រូវស្របតាមព្រះបន្ទូលរបស់ព្រះ។ ព្រះគម្ពីរសញ្ញាថ្មីក៏បង្រៀនថា មានពួកចាស់ទុំនៅក្នុងពួកជំនុំ ដែលមានទំនួលខុសត្រូវពិសេសមួយក្នុងការបង្រៀនព្រះបន្ទូលរបស់ព្រះ ប៉ុន្តែនេះមិនហាមអ្នកដទៃទៀតនៅក្នុងពួកជំនុំមិនអោយនិយាយឡើយ។ សេចក្តីពិតដែលថា គ្រីស្ទបរិស័ទទាំងអស់គឺជាសង្ឃ មិនផ្តល់ព័ន្ធកិច្ច/ (ការបម្រើ)ស្មើគ្នាទៅចំពោះគ្រីស្ទបរិស័ទគ្រប់គ្នានោះទេ ប៉ុន្តែផ្តល់ការបម្រើដល់មនុស្សទាំងអស់ ដោយព្រះគ្រីស្ទចែកព័ន្ធកិច្ច (ការបម្រើ) ពិសេស ដែលទាក់ទងនឹងអំណាចទៅកាន់មនុស្សមួយចំនួន។ ទោះយ៉ាងណា ព័ន្ធកិច្ចពិសេស ដែលព្រះគ្រីស្ទបានប្រទានដល់មនុស្សមួយចំនួន គឺជាការបង្រៀននិងការដឹកនាំតាមរយៈការបង្រៀនព្រះបន្ទូលរបស់ព្រះ គឺមិនមែនប្រទានអោយធ្វើជាអ្នកសម្របសម្រួល (ស្ពានមេត្រី) រវាងព្រះជាម្ចាស់និងមនុស្ស ឬសង្ឃឡើយ។

## ការយល់ខុសអំពី «សង្ឃ» (បូជាចារ្យ) នៅក្នុងប្រវត្តិសាស្រ្តពួកជំនុំ

នៅក្នុងប្រវត្តិសាស្រ្ត ពួកជំនុំរ៉ូម៉ាំងកាតូលិកបានបង្កកំហុសមួយគឺ បានហៅពួកអ្នកដឹកនាំរបស់ខ្លួនជាពួកបូជាចារ្យ ហើយបានផ្លាស់ប្តូរតួនាទីរបស់ពួកអ្នកដឹកនាំរបស់ពួកគេដូចកាន់តែដូចជាពួកសង្ឃ (បូជាចារ្យ) នៅក្នុងព្រះគម្ពីរសញ្ញាចាស់។ ពួកគេបានចាត់ទុកពួកសង្ឃរបស់ពួកគេជាពួកអ្នកសម្រួបសម្រួមរវាងព្រះនិងសមាជិកពួកជំនុំ ហើយបានថ្វាយយញ្ញបូជាជំនួសមនុស្សទៀតផង។ ពួកគេបានថ្វាយយញ្ញបូជាក្នុងកំឡុងពេលធ្វើពិធីអរព្រះគុណព្រះអម្ចាស់ (ពិធីជប់លៀងព្រះអម្ចាស់ដែលគេហៅថា Mass) ដោយពួកគេជឿថា នៅពេលបូជាចារ្យបានបំពេញតួនាទីពិសេសរបស់គាត់ហើយ នោះនំប៉័ង និងស្រានឹងផ្លាស់ប្រែទៅជារូបកាយ និង លោហិតរបស់ ព្រះគ្រីស្ទ ហើយសង្ឃថ្វាយព្រះគ្រីស្ទជាយញ្ញបូជាសម្រាប់មនុស្ស។

កំហុសនេះដែលយល់ច្រឡំថា ពួកអ្នកដឹកនាំពួកជំនុំគឺជាសង្ឃ (បូជាចារ្យ) ដូចនៅក្នុងព្រះគម្ពីរសញ្ញាចាស់គឺបានចាប់ផ្តើមអភិវឌ្ឍន៍នៅចុងសតវត្សទីមួយ។ ក្លេមិន (Clement) (ប្រហែលឆ្នាំ៩៥) បានប្រើឋានានុក្រមមានបីថ្នាក់ដែលមាននៅក្នុងសញ្ញាចាស់(គឺ សម្តេចសង្ឃ ពួកសង្ឃ និងពួកលេវី) មកអនុវត្តចំពោះអ្នកដឹកនាំពួកជំនុំគ្រីស្ទបរិស័ទដែរ។ ធឺទូលាន (Tertullian) (ប្រហែលឆ្នាំ២០០) បានប្រើពាក្យថា «សង្ឃ» (បូជាចារ្យ) និង «សម្តេចសង្ឃ» សម្រាប់ពួកគ្រូគង្វាលរបស់ពួកជំនុំ។ នៅក្នុងសតវត្សទី១៣ មានការបង្កើតប្រព័ន្ធមួយ ដែលពួកសង្ឃរ៉ូម៉ាំងកាតូលិកគឺជាក្រុមពិសេសមួយ ដែលអាចបំពេញតួនាទី (តំណែង) សាសនា ដែលគ្មានអ្នកណាផ្សេងទៀតអាចធ្វើបានឡើយ។ ប្រសិទ្ធិភាពពិធីសាសនា ដែលបូជាចារ្យបានធ្វើ គឺអាស្រ័យលើបូជាចារ្យ ដូច្នេះហើយ ជំនឿរបស់ក្រុមជំនុំត្រឡប់ទៅជាមិនសូវសំខាន់។ គេតម្រូវអោយសមាជិកពួកជំនុំសារភាពអំពើបាបរបស់ខ្លួនទៅកាន់បូជាចារ្យ ពីព្រោះគាត់មានដើរតួនាទីជាអ្នកសង្រ្គប់សង្រ្គមរវាងព្រះ និងសមាជិកពួកជំនុំ។ បូជាចារ្យមានអំណាចអត់ទោស (ឬមិនអត់ទោស) អំពើបាបរបស់មនុស្សបាន។

## ការកំណែទម្រង់

នៅពេលមានការកំណែទម្រង់ ហើយពួកជំនុំប្រូតេស្តង់បានចាប់ផ្តើម សេចក្តីពិតមួយរបស់ព្រះគម្ពីរ ដែលពួកគេបានសង្កត់ធ្ងន់លើគឺ គ្រីស្ទបរិស័ទទាំងអស់ជាសង្ឃ។ ពួកអ្នកដឹកនាំពួកជំនុំមិនមែនជាពួកសង្ឃពិសេស ពួកគេមិនមែនជាពួកអ្នកសង្រ្គប់សង្រ្គមរវាងព្រះ និងពួកជំនុំ ហើយពួកគេមិនថ្វាយយញ្ញបូជានៅពេលពួកគេធ្វើពិធីអរព្រះគុណព្រះអម្ចាស់នោះឡើយ។ នំប៉័ង និងស្រាមិនប្រែទៅជារូបកាយ និងលោហិតរបស់ព្រះគ្រីស្ទឡើយ។ គ្រីស្ទបរិស័ទមិនចាំបាច់សារភាពអំពើបាបរបស់ខ្លួនទៅកាន់សង្ឃ ដើម្បីអោយគាត់ប្រកាសអោយរួចពីអំពើបាបរបស់ពួកគេឡើយ។ ពួកអ្នកកំណែទម្រង់បានបដិសេធគោលលទ្ធិទាំងអស់នេះ ពីព្រោះពួកគេបានងាកបែរមកឯសេចក្តីពិតតាមព្រះគម្ពីរសញ្ញាថ្មី ដែលយើងបានមើលឃើញខាងលើហើយ។

## ការសន្និដ្ឋាន

ដោយសារការសុគតរបស់ព្រះយេស៊ូវ នោះព្រះវិហារ និងតំណែងជាសង្ឃនៅក្នុងព្រះគម្ពីរសញ្ញាចាស់ត្រូវបានបញ្ចប់ ហើយឥឡូវនេះព្រះយេស៊ូវគឺជាអ្នកសង្រ្គប់សង្រ្គម (ស្ពានមេត្រី) តែមួយគត់រវាងព្រះ និងមនុស្ស។ ការបន្ថែមថាពួកសង្ឃជាពួកអ្នកសម្របសម្រួលរវាងព្រះ និងមនុស្សគឺធ្វើអោយដំណឹងល្អខុសពីភាពដើម។ ព្រះបានត្រាស់ហៅគ្រីស្ទបរិស័ទទាំងអស់អោយធ្វើជាសង្ឃ ដែលមានន័យថា យើងមិនហៅពួកអ្នកដឹកនាំពួកជំនុំជាពួកសង្ឃ ឬបូជាចារ្យនោះទេ ហើយគ្រីស្ទបរិស័ទទាំងអស់ត្រូវតែមានជីវិតបរិសុទ្ធ ថ្វាយជីវិតទាំងស្រុងរបស់ពួកគេជាយញ្ញបូជារស់ទៅចំពោះព្រះ ហើយស្អាងគ្នាឡើងនៅក្នុងរូបកាយរបស់ព្រះគ្រីស្ទ។

## Bibliography

Cairns, A. (2002). In *Dictionary of Theological Terms*. Belfast; Greenville, SC: Ambassador Emerald International.

Carver, D. E. (2014). Priesthood. D. Mangum, D. R. Brown, R. Klippenstein, & R. Hurst (Eds.), *Lexham Theological Wordbook*. Bellingham, WA: Lexham Press.

Currid, J. D. (2001). *A Study Commentary on Exodus: Exodus 19–40* (Vol. 2). Darlington, England; Carlisle, PA: Evangelical Press.

Duffield, G. P., & Van Cleave, N. M. (1983). *Foundations of Pentecostal theology*. Los Angeles, CA: L.I.F.E. Bible College.

Elwell, W. A., & Beitzel, B. J. (1988). In *Baker encyclopedia of the Bible*. Grand Rapids, MI: Baker Book House.

Ferguson, S. B., & Packer, J. I. (2000). In *New dictionary of theology*. Downers Grove, IL: InterVarsity Press.

Hacking, P. H. (2006). *Opening up Hebrews*. Leominster: Day One Publications.

Harrison, R. K. (1980). *Leviticus: an introduction and commentary* (Vol. 3). Nottingham, England: Inter-Varsity Press.

Kendall, R. T. (1996). *Understanding Theology, Volume One*. Ross-shire, Great Britain: Christian Focus.

(1988). *Grace Theological Journal*, *9*.

Mostert, J. (1967). Preparing the Laity to Teach. In R. G. Turnbull (Ed.), *Baker's dictionary of practical theology*. Grand Rapids, MI: Baker Book House.

Motyer, J. A. (1984). *The message of Philippians*. Leicester; Downers Grove, IL: Inter-Varsity Press.